**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

## សេចក្តីប្រកាសព័ត៌មាន

## នាយករដ្ឋមន្ត្រីកម្ពុជា និងថៃ ជួបពិភាក្សាអំពីកិច្ចសហប្រតិបត្តិការទ្វេភាគី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង**ឯកឧត្តម ឧត្តមសេនីយ៍ ប្រាយុទ្ធ ច័ន្ទអូចា** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រថៃ បានវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការដ៏ល្អលើគ្រប់វិស័យដែលកំពុងមាននៅពេលបច្ចុប្បន្ន រវាងប្រទេសទាំងពីរ ដែលឈរលើស្មារតីជាអ្នកជិតខាងល្អ មិត្តភាពជាប្រពៃណី និងការជឿជាក់គ្នាទៅវិញទៅមក នៅក្នុងជំនួបទ្វេភាគី នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២២ ក្នុងឱកាសនៃកិច្ចប្រជុំកំពូលអាស៊ាន លើកទី៤០ និង៤១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ នៅរាជធានីភ្នំពេញ។ នាយករដ្ឋមន្ត្រីទាំងពីរ បានសម្តែងការពេញចិត្តចំពោះវឌ្ឍនភាពដ៏គួរឱ្យកត់សម្គាល់នៃកិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ និងបានឯកភាពគ្នាក្នុងការពង្រីក និងធ្វើឱ្យស៊ីជម្រៅបន្ថែមទៀតនូវទំនាក់ទំនងដ៏ជិតស្និទ្ធនេះ។

**សម្តេចតេជោនាយករដ្ឋមន្ត្រី** បានបញ្ជាក់អំពីការគាំទ្រយ៉ាងពេញទំហឹងរបស់កម្ពុជា និងបានជូនពរប្រទេសថៃឲ្យទទួលបានជោគជ័យក្នុងការធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូល APEC នាពេលខាងមុខ និងបានសម្តែងនូវសេចក្តីសោមនស្សរីករាយ ក្នុងការទទួលយកការអញ្ជើញទៅចូលរួមក្នុងកិច្ចប្រជុំកំពូលនេះ នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២២ ក្នុងឋានៈជា «ភ្ញៀវរបស់ម្ចាស់ផ្ទះ»។

នាយករដ្ឋមន្ត្រីទាំងពីរ បានគូសបញ្ជាក់អំពីសារៈសំខាន់នៃការបន្តឡើងវិញនូវកិច្ចប្រជុំគណៈរដ្ឋមន្ត្រីចម្រុះ (JCR) រវាងប្រទេសទាំងពីរ ដែលជាយន្តការខ្ពស់បំផុតនៃកិច្ចសហប្រតិបត្តិការទ្វេភាគី បន្ទាប់ពីការផ្អាកមួយរយៈដោយសារជំងឺរាតត្បាត។ **ឯកឧត្តម ឧត្តមសេនីយ៍ ប្រាយុទ្ធ ច័ន្ទអូចា** បានបញ្ជាក់ថា ប្រទេសថៃនឹងទទួលធ្វើជាម្ចាស់ផ្ទះ JCR លើកទី៤ តាមពេលវេលាមួយសមស្រប។

ថ្នាក់ដឹកនាំទាំងពីរ បានកត់សម្គាល់ដោយការពេញចិត្តចំពោះកំណើននៃការផ្លាស់ប្តូរពាណិជ្ជកម្មទ្វេភាគី ចំពេលនៃបញ្ហាប្រឈមនានាបង្កឡើងដោយជំងឺរាតត្បាតកូវីដ-១៩ និងបានពិភាក្សាអំពីវិធានការជាក់ស្តែង ដើម្បីជំរុញបន្ថែមទៀតនូវទំហំនៃការផ្លាស់ប្តូរនេះឲ្យកើនដល់គោលដៅចំនួន ១៥ប៊ីលានដុល្លារអាមេរិក នៅក្នុងរយៈពេល២ឆ្នាំ។ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានស្នើឱ្យភាគីថៃ

អាសយដ្ឋាន: លេខ ៣ វិថី **សម្តេច ហ៊ុន សែន**
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

ជួយទិញអង្ករកម្ពុជាបន្ថែមទៀត និងជួយសម្រួលនីតិវិធីនៃការនាំចូលកសិផលកម្ពុជាឆ្លងកាត់ព្រំដែនចូលទៅប្រទេសថៃ។

**សម្តេចតេជោនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណរាជរដ្ឋាភិបាលថៃ ដែលបានជួយសម្រួលដល់ពលករកម្ពុជានៅប្រទេសថៃ ជាពិសេសក្នុងអំឡុងពេលនៃការរាតត្បាតនៃជំងឺកូវីដ-១៩ និងបានស្នើសមភាគីថៃឱ្យបន្តកិច្ចសហប្រតិបត្តិការជិតស្និទ្ធនៅក្នុងកិច្ចការនេះ។

ដើម្បីជំរុញពាណិជ្ជកម្មតាមព្រំដែន និងទំនាក់ទំនងរវាងប្រជាជននិងប្រជាជន នាយករដ្ឋមន្ត្រីទាំងពីរបានឯកភាពប្រគល់ភារកិច្ចដល់អាជ្ញាធរពាក់ព័ន្ធនៃប្រទេសទាំងពីរ ដើម្បីពន្លឿនការបើកដំណើរការច្រកទ្វារអន្តរជាតិស្ទឹងបត់-បានណងអៀន និងការបើកដំណើរការ «ស្ពានមិត្តភាព» ឱ្យបានឆាប់ហើយនិងអនុវត្តកិច្ចព្រមព្រៀងដែលសម្រេចបាន ក្នុងកិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃនាពេលថ្មីៗនេះ ដើម្បីជំរុញការអភិវឌ្ឍតំបន់ព្រំដែន។

ថ្នាក់ដឹកនាំទាំងពីរ ក៏បានសង្កត់ធ្ងន់លើសារៈសំខាន់នៃការពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យអប់រំការអភិវឌ្ឍធនធានមនុស្ស វិស័យការពារជាតិនិងសន្តិសុខ ទេសចរណ៍ ការតភ្ជាប់ផ្លូវដែក ថាមពលស្អាត ការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ដូចជា ការឆ្លងដែនខុសច្បាប់ និងការជួញដូរមនុស្ស។ ថ្នាក់ដឹកនាំទាំងពីរ ក៏បានពិភាក្សាគ្នាផងដែរអំពីការផ្លាស់ប្តូរការគាំទ្រគ្នាលើឆាកអន្តរជាតិ ។

**សម្តេចតេជោនាយករដ្ឋមន្ត្រី** និង**ឯកឧត្តម ឧត្តមសេនីយ៍ ប្រាយុទ្ធ ច័ន្ទអូចា** ក៏បានផ្លាស់ប្តូរយោបល់លើបញ្ហាប្រឈមនានាដែលអាស៊ានកំពុងជួបប្រទះ ព្រមទាំងបញ្ហាតំបន់ និងអន្តរជាតិមួយចំនួនដែលជាកង្វល់រួម ផងដែរ។ **ឯកឧត្តម ឧត្តមសេនីយ៍ ប្រាយុទ្ធ ច័ន្ទអូចា** បានជូនពរ**សម្តេចតេជោនាយករដ្ឋមន្ត្រី** ឱ្យទទួលបានជោគជ័យក្នុងការរៀបចំកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០ និងទី៤១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធនានា នៅរាជធានីភ្នំពេញ៕

ថ្ងៃព្រហស្បតិ៍ ២រោច ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២២